ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងសាងសង់រថភ្លើងលើអាកាស ធុនស្រាល នៅក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសម្បទាន
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការ សិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងសាងសង់រថភ្លើងលើអាកាស ធុនស្រាល នៅក្នុងរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម គាត ឈន់ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២- ឯកឧត្តម យឹម ឆៃលី | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៤- ឯកឧត្តម នួន ពន្ធរ័ត្ន | ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អនុប្រធាន |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| | | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | |
| ៥- | ឯកឧត្តម សុខ ចិន្តា | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី<br>អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ៧- | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | | សមាជិក |
| ៨- | រដ្ឋលេខាធិការក្រសួងបរិស្ថាន | | សមាជិក |
| ៩- | ឯកឧត្តម តូច ចាន់កុសល | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១០- | ឯកឧត្តម ទន្សី ចិរស្សេត | អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១- | ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | | សមាជិក |
| ១២- | ឯកឧត្តម ទាវ ស៊ីមស៊ីយ៉ា | អគ្គនាយករដ្ឋបាល នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៣- | ឯកឧត្តម ម៉ែន សុគន្ធធីឌី | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី | សមាជិក |
| ១៤- | នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | លេខាធិការដ្ឋាន |

**ប្រការ ២ :** គណៈកម្មការ សិក្សាសមិទ្ធិលទ្ធភាពគម្រោងសាងសង់រថភ្លើងលើអាកាស ធុនស្រាល នៅក្នុងរាជធានីភ្នំពេញ មានភារកិច្ចដូចខាងក្រោម ÷

- ធ្វើការសិក្សា វាយតំលៃលើរបាយការណ៍សមិទ្ធិលទ្ធភាពនៃគម្រោង ជាពិសេសទិដ្ឋភាពបច្ចេកទេស និងផ្នែកនគរូបនីយកម្ម ក្នុងការសាងសង់។
- សិក្សា និងធ្វើការវិភាគអំពីប្រសិទ្ធភាពខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់គម្រោង។

**ប្រការ ៣ :** គណៈកម្មការ សិក្សាសមិទ្ធិលទ្ធភាពគម្រោងសាងសង់រថភ្លើងលើអាកាស ធុនស្រាល នៅក្នុងរាជធានីភ្នំពេញ មានសិទ្ធិបង្កើតអនុគណៈកម្មការបច្ចេកទេសមួយចំនួន ជាជំនួយការ តាមការចាំបាច់។

**ប្រការ ៤ :** អនុប្រធាន និងសមាជិក ត្រូវចូលរួមការប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ។

**ប្រការ ៥ :** ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង- ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ៧ ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *រាជកិច្ច*

www.pheakdeylaw.com